**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ២ រោច ខែ ភទ្របទ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា គ.ស. ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ជំនួបសម្តែងការគួរសមរវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ឯកឧត្តម អ៊ីហ្គ្វ ទ្រីសម៉ាន់ (Igor Driesmans) ឯកអគ្គរដ្ឋទូតនៃប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា

នារសៀលថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០២៤, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** បានទទួលជួប **ឯកឧត្តម អ៊ីហ្គ្វ ទ្រីសម៉ាន់** (Igor Driesmans) **ឯកអគ្គរដ្ឋទូតនៃប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា** ពិភាក្សាលើទិដ្ឋភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគី, ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់វិស័យអប់រំ និងការវិនិយោគនៅកម្ពុជាក្នុងបរិបទយុទ្ធសាស្ត្រ Global Gateway ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ និងបញ្ជាក់ជូនអំពីកិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងរាជរដ្ឋាភិបាលអាណត្តិទី ៧ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រកបដោយភាពស្វាហាប់ និងរឹងមាំ ក្នុងនោះ ទោះបីជាក្នុងកាលៈទេសៈនៃភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល និងបញ្ហាភូមិសាស្ត្រនយោបាយ, ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា បាន និងកំពុងស្ថិតនៅលើគន្លងវិថីដ៏ត្រឹមត្រូវ ដែលកំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅក្នុងឆ្នាំ ២០២៤ អាចនឹងសម្រេចបានក្នុងរង្វង់ ៦% និងបន្តធានាស្ថិរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ជាមួយនឹងការថ្លែងអំណរគុណចំពោះសហភាពអឺរ៉ុប ដែលបានផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញប្បទានលើគ្រប់វិស័យ, ភាគីទាំងពីរបានពិភាក្សាផ្លាស់ប្តូរយោបល់លើស្ថានភាពសេដ្ឋកិច្ចសកល តំបន់អឺរ៉ុប ក៏ដូចជាតំបន់អាស៊ីដែលបានជះឥទ្ធិពលដោយផ្ទាល់ និងប្រយោលមកលើសេដ្ឋកិច្ចកម្ពុជា, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ជូនអំពីវិធានការនានាដែលកម្ពុជាបានដាក់ចេញ ដើម្បីជំរុញសេដ្ឋកិច្ចកម្ពុជាឲ្យងើបឡើងវិញបន្ទាប់ពីវិបត្តិនៃការរាលដាលរបស់ជំងឺកូវីដ ១៩ និងភូមិសាស្ត្រនយោបាយ, ដូចជា វិធានការក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការខិតខំពង្រឹងក្នុងការកៀរចំណូល និងចំណាយសាធារណៈ, ពន្ធដារ, ការគ្រប់គ្រងអចលនទ្រព្យ... 

**ឯកឧត្តមឯកអគ្គរដ្ឋទូតនៃប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា** ក៏បានបង្ហាញជំហរក្នុងការគាំទ្រ និងចូលរួមយ៉ាងសកម្ម ក្នុងការជំរុញការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់វិស័យអប់រំ នៅកម្ពុជា ទាំងក្នុង

ទម្រង់ជាថវិកាគាំទ្រ និងជំនួយបច្ចេកទេស ។ លោកក៏បានគូសបញ្ជាក់ពីយុទ្ធសាស្ត្រ Global Gateway គឺជាឧបករណ៍ដ៏មានតម្លៃសម្រាប់ការទាក់ទាញការវិនិយោគរបស់សហភាពអឺរ៉ុប និងជំរុញកំណើនប្រកបដោយចីរភាព៖ "សហភាពអឺរ៉ុបបានបង្ហាញជំហរប្តេជ្ញាចំពោះភាពជាដៃគូរបស់ខ្លួនជាមួយប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរបៃតង និងឌីជីថល និងរួមដំណើរជាមួយប្រទេសកម្ពុជា ក្នុងការចាកចេញពីចំណាត់ថ្នាក់ប្រទេសអភិវឌ្ឍន៍តិចតួច ។ យុទ្ធសាស្ត្រវិនិយោគ Global Gateway នឹងក្លាយជាឧបករណ៍របស់សហភាពអឺរ៉ុបសម្រាប់កម្ពុជានៅក្នុងដំណាក់កាលនេះ ។"

ជាចុងបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណជាថ្មីម្តងទៀតចំពោះសហភាពអឺរ៉ុបដែលគាំទ្រកម្ពុជាដើម្បីការអភិវឌ្ឍលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា, ទាំងផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញប្បទាន, ជាពិសេស ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីដំណាក់កាលទី ១ "**ភាពជឿទុកចិត្តនៃថវិកា**" រហូតដល់ដំណាក់កាលទី ៤ "**គណនេយ្យភាពសមិទ្ធកម្ម**" នាពេលបច្ចុប្បន្ន ។